# "ខ្ញុំ" ក្នុងសិលាចារឹកខ្មែរ

**"ខ្ញុំ"** និង **"ក្ញុំ"** ជាពាក្យតែមួយ ប៉ុន្តែសរសេរក្នុងកាលវេលាខុសគ្នា។ ក្នុងសិលាចារឹកសម័យមុនអង្គរ និងដើមសម័យអង្គរ តែងឃើញគេសរសេរជា **ក្ញុំ** លុះក្រោយមកក្នុងសម័យអង្គរគេសរសេរជា **ខ្ញុំ**។ សិលាចារឹកជាច្រើនបង្ហាញពីបញ្ជី **"ខ្ញុំ"** រាប់រយពាន់នាក់ដែលគេបានធ្វើអំណោយទៅប្រាសាទ ឬទៅបម្រើទេព ដោយពួកគេមានតួនាទីដោយឡែកៗពីគ្នា ដូចជាដុតភ្លើងបំភ្លឺ យាមទ្វារ ដាំស្ល ធ្វើស្រែចំការជាដើម (រូបលេខ១-២)។ តាមរយៈការសិក្សារបស់អ្នកស្រាវជ្រាវធំៗជាច្រើនក៏ដូចជា លោក ហ្សក សឺដេស ដែលជាអ្នកសិក្សាសិលាចារឹកខ្មែរដ៏ល្បីបានសន្និដ្ឋានថា ពាក្យ **"ខ្ញុំ"** ក្នុងសិលាចារឹកភាសាខ្មែរ ត្រូវគ្នានឹងពាក្យ **"ទាសា ទាសី"** ក្នុងសិលាចារឹកសំស្ក្រឹត ហើយអាចប្រែជាភាសាបារាំងថា Esclave ឬ Slave ជាភាសាអង់គ្លេស ។

**តើ "ខ្ញុំ" ជាអ្វី?**

ក្នុងសង្គមខ្មែរសព្វថ្ងៃ **"ខ្ញុំ"** ជាសព្វនាមបុរសទី១ ហើយអាចប្រើផ្សំ និងពាក្យផ្សេងៗដូចជា ខ្ញុំបាទ នាងខ្ញុំ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណាខ្ញុំ ខ្ញុំឯង ជាដើម។ ក្រៅពីនោះ **"ខ្ញុំ"** ក៏ប្រើបញ្ជាក់ស្ថានភាពរបស់មនុស្សផងដែរដូចជា ខ្ញុំគេ ខ្ញុំបម្រើ ខ្ញុំកញ្ជះ ខ្ញុំកំដរ ខ្ញុំរាជការ។ល។

ក្នុងវចនានុក្រមសម្តេចសង្ឃ ជួន ណាត **"ខ្ញុំ"** មានន័យថា មនុស្សក្រីក្រ ដែលជំពាក់បំណុលគេ ហើយក៏មានន័យម្យ៉ាងទៀតស្មើនឹងពាក្យថា **"ទាសា (ខ្ញុំប្រុស) ទាសី (ខ្ញុំស្រី)"** ដូចក្នុងសិលាចារឹកខ្មែរបុរាណដែរ[១]។ គួរឲ្យកត់សម្គាល់ថា ពាក្យ **"ទាសា ទាសី"** នៅបន្តប្រើប្រាស់ក្នុងព្រះបរមរាជវាំងនៅឡើយ។

ក៏ប៉ុន្តែដើម្បីឲ្យយល់កាន់តែច្បាស់ពីអ្វីជា **"ខ្ញុំ"** គួរពិនិត្យអត្ថន័យ និងបរិបទនៃការប្រើប្រាស់ពាក្យ **"ទាសា ទាសី"** ក្នុងសង្គមឥណ្ឌាផងដែរ។ ពាក្យ **"ទាសា ទាសី"** ចេញមកពីឬស **"ទាស"** ដែលសំដៅន័យថា ខ្មៅ ឬមនុស្សមានជាតិសម្បុរខ្មៅ ដែលនិយមន័យនេះជាប់ទាក់ទងនឹងការងារកសិកម្ម[២]។ ពាក្យនេះលេចឡើងនៅក្នុងគម្ពីរល្បីៗរបស់ឥណ្ឌាដូចជា

---

[១] ណាត ១៩៦៨:១០៧

[២] Sharad Patil 1982:240

អត្ថបទដោយ៖ កញ្ញា **មាស សុភាព**

*ឫកវេទជាដើម ហើយប្រើប្រាស់ក្នុងន័យថាជា អ្នកបម្រើ។ ទន្ទឹមនឹងនោះ អ្នកស្រាវជ្រាវលោក លូដូ រូឆេ បានបញ្ជាក់ថា "**ទាសា ទាសី**" ក៏អាចមានន័យថា "**សូទ្រ**" ដែរ គឺមនុស្សដែលគេចាត់ចូលក្នុងជំពូកទី៤ក្នុងសង្គមឥណ្ឌា ដែលប្រកបការងារដោយប្រើកំលាំង និងហត់នឿយជាដើមនោះ[៣]។ ដូច្នេះបើពិនិត្យទៅលើអត្ថន័យរបស់ពាក្យ "**ខ្ញុំ**" ព្រមទាំងកិច្ចការងារប្រចាំថ្ងៃដែលមានបញ្ជាក់ក្នុងសិលាចារឹកខ្មែរបុរាណ គឺស្របគ្នានឹងកិច្ចការងាររបស់ "**ទាសា ទាសី**" មិនត្រឹមតែក្នុងសិលាចារឹកសំស្ក្រឹតខ្មែរបុរាណទេ ប៉ុន្តែនៅក្នុងសង្គមឥណ្ឌាផងដែរ។ លើសពីនោះទៅទៀត ន័យរបស់ពាក្យ "**ខ្ញុំ**" មិនដែលផ្លាស់ប្តូរទេក្នុងសង្គមខ្មែរ គឺ "**ខ្ញុំ**" មានន័យត្រឹមតែជាអ្នកបម្រើ ឬមានន័យបង្កប់នូវការគោរពអ្នកដទៃដ៏ជ្រាលជ្រៅ។*

*ឧទាហរណ៍ **ខ្ញុំរាជការ**។ ពាក្យខ្ញុំរាជការ មានន័យល្អណាស់។ ខ្ញុំរាជការ គឺជាអ្នកបម្រើការងារផ្សេងៗជូនទៅរាជការ។ ពួកគាត់ទទួលបានផលប្រយោជន៍គ្រប់គ្រាន់ កេរ្តិ៍ឈ្មោះ ឬប្រាក់កម្រៃសម្រាប់ចិញ្ចឹមជីវិតដោយសមរម្យ។*

*ឧទាហរណ៍ម្យ៉ាងទៀត ព្រះមហាក្សត្រ ព្រះអង្គតែងមានព្រះឱសជាប្រក្រតីថា **ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណាខ្ញុំ**។ បើសង្កេតមើលន័យនេះ ពាក្យ "**ខ្ញុំ**" ទាំងបីប្រហែលជាអាចសំដៅន័យបីផ្សេងគ្នា។ ទី១ សព្វនាម ទី២ ការគោរព ទី៣ បញ្ជាក់ពីភារកិច្ចការងារ។ ព្រះមហាក្សត្រ ព្រះអង្គគឺជាទីគោរពសក្ការតម្កល់លើត្បូងរបស់ប្រជានុរាស្ត្រ ប៉ុន្តែព្រះអង្គបានបូជាព្រះកាយពលរបស់ព្រះអង្គបម្រើរាស្ត្រទូទាំងប្រទេស។ ដូច្នេះការប្រើប្រាស់ពាក្យ "**ខ្ញុំ**" គ្រប់ស្រទាប់វណ្ណៈក្នុងសង្គមខ្មែរមិនមែនជាការចៃដន្យ ឬដោយគ្មានអត្ថន័យវិសេសវិសាលនោះឡើយ។ ម្យ៉ាងទៀត ប្រសិនបើ "**ខ្ញុំ**" សំដៅដល់ភាពឈឺចាប់ និងទុក្ខវេទនា ខ្មែរប្រហែលមិនប្រើពាក្យនេះសម្គាល់ខ្លួនឯងនោះទេ។*

*សរុបមក "**ខ្ញុំ**" ទាំងឡាយដែលមានបញ្ជាក់ក្នុងសិលាចារឹកខ្មែរបុរាណ គឺជាក្រុមមនុស្សដែលប្រកបកិច្ចការងារបម្រើព្រះ និងប្រាសាទ ហើយដែលប្រភេទកិច្ចការងារ ព្រមទាំងបរិបទសង្គមនាសម័យនោះ មិនអាចទាញសន្និដ្ឋានថា ពួក "**ខ្ញុំ**" ទាំងនោះគឺជា **ទាសករ** ដូចការយល់ក្នុងពេលបច្ចុប្បន្ន ឬដែលបារាំងប្រែថា* Esclave *និងអង់គ្លេសថា* Slave *នោះទេ។*

[៣] Ludo Rocher 2002 : 377

*អត្ថបទដោយ៖ កញ្ញា **មាស សុភាព***



រូបលេខ១៖ ខ្ញុំកំពុងដាំស្ល



រូបលេខ២៖ ខ្ញុំធ្វើដំណើរ

## ឯកសារយោង

អត្ថបទដោយ៖ កញ្ញា មាស សុភាព

ជួន ណាត

១៩៦៨. វចនានុក្រមខ្មែរ,ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ។

**Sharad Patil.**

1982. *Dasa-Sudra Slavery: Studies in the origins of Indian Slavery and Feudalism and Their Philosophies.* Delhi: Allied Publisher Private Limited.

**Ludo Rocher.**

2002. "Dāsadāsī," *Journal of American Oriental Society* 122, no 2.